## ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជានៅព្រះសហគមន៍សន្តយ៉ូសែប
## ផ្សារតូច ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០
## ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងឥស៊ូគ្រប់កាលៈទេសៈ

**អត្ថបទទី១៖ កិច្ចការ ៦,១-៧**

គ្រីស្តទូតទាំងដប់ពីររូបក៏កោះហៅពួកសាវ័កទាំងអស់មក ហើយមានប្រសាសន៍ថា៖ «មិនគួរឲ្យយើងខ្ញុំ ចោលការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅបម្រើតុឡើយ។ កក ៦,២

**អត្ថបទទី២៖ ពេត្រុសទី១ ២,៤-៩**

សូមបងប្អូនចូលមកជិតព្រះគ្រីស្ត ជាសិលាដ៏មានជីវិត ជាសិលាដែលមនុស្សលោកបានបោះបង់ចោល តែព្រះជាម្ចាស់បានរើសយក ព្រោះទ្រង់ឈ្វេងយល់ថាមានតម្លៃវិសេស។ ១ពត្រ ២,៤

**ដំណឹងល្អ៖ យ៉ូហាន ១៤,១-១២**

ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ «ខ្ញុំហ្នឹងហើយជាផ្លូវ ជាសេចក្តីពិត និងជាជីវិត។ គ្មាននរណាម្នាក់អាចទៅកាន់ព្រះបិតាបានឡើយ លើកលែងតែទៅតាមរយៈខ្ញុំ។ យហ ១៤,៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងបន្តស្តាប់អំពីជីវិតរបស់ព្រះសហគមន៍ពីសម័យដើម របៀបដែលក្រុមគ្រីស្តទូតរួមជាមួយគ្រីស្តបរិស័ទពីសម័យដើម បានរៀបចំព្រះសហគមន៍។ ថ្ងៃនេះ ក្រុមគ្រីស្តទូតបាននិយាយថា "**មិនគួរឲ្យយើងចោលការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទៅបម្រើតុឡើយ**"។ ហេតុនេះហើយគេបានជ្រើសរើស ៧នាក់នៅក្នុងចំណោមគ្រីស្តបរិស័ទ ជាមនុស្សដែលមានកេរ្តិ៍ឈ្មោះ ពោរពេញដោយព្រះវិញ្ញាណនិងប្រាជ្ញាឈ្លៀសវៃ ដើម្បីទទួលតួនាទី «**បម្រើតុ**» មានន័យថាបម្រើធម៌មេត្តាករុណា បម្រើអ្នកក្រីក្រ បម្រើស្ត្រីមេម៉ាយ កុមារកំព្រា មនុស្សដែលខ្វះខាត។ ក្រុមគ្រីស្តទូតគេទុកសម្រាប់ណែនាំការអធិដ្ឋាន ណែនាំអគ្គសញ្ញាអភិបូជា និងពិធីជ្រមុជទឹក។ ពីដើម គ្រីស្តបរិស័ទបានរៀបចំព្រះសហគមន៍ យើងកំពុងនិយាយ២០០០ឆ្នាំមុនដែលមានបរិកាសមិនស្រួលប៉ុន្មានទេ ដោយសារយើងបានស្តាប់កិច្ចការគ្រីស្តទូត ប៉ុន្មានរឿងហើយមានគេប្តឹងមានគេចាប់ក្រុមគ្រីស្តទូត ក្រុមគ្រីស្តទូតត្រូវគេបណ្តេញពីក្រុងយេរ៉ូសាឡឹមទៅទីក្រុងអន់ទីយ៉ូកពីក្រុងអន់ទីយ៉ូកទៅក្រុងផ្សេងទៀត។ ដូច្នេះ ជាសម័យដែលមានបញ្ហាច្រើន ទោះបីមានមនុស្សច្រើនដែលសុខចិត្តចូលជាសាវ័កព្រះគ្រីស្ត ប៉ុន្តែគេទទួលការបៀតបៀនច្រើន។ នៅពេលគេទទួលការបៀតបៀនមួយ គេទៅរកផ្លូវថ្មីដើម្បីបន្តបម្រើ ដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់អធិដ្ឋាន និងសម្តែងធម៌មេត្តាករុណាជានិច្ចសម្រាប់អ្នកក្រីក្រ។ ដូច្នេះ ថ្ងៃនេះយើងឃើញមានក្រុម

ពីរ មានក្រុមគ្រីស្តទូតដូចជាបូជាចារ្យពីដើមដែលចាប់ផ្តើមបម្រើការអធិដ្ឋាន ពិធីបុណ្យនានា និងក្រុមឧបដ្ឋាក៧នាក់ ដែលទទួលខុសត្រូវបម្រើអ្នកក្រីក្រ។

នៅក្នុងឆ្នាំ៣០ ព្រះសហគមន៍ចាប់ផ្តើមធ្វើដំណើរ ចេញពីទីក្រុងយេរូសាឡឹមទៅជុំវិញសមុទ្រមេឌីទែរ៉ាណេរហូតទៅដល់ទីក្រុងរ៉ូម។ ដូច្នេះ ព្រះសហគមន៍ចាប់ផ្តើមចេញពីកន្លែងកំណើត គឺកន្លែងដែលមានសាសនាយូដា។ សាសនាយូដា ដែលមានសម្ពន្ធមេត្រីចាស់ ដែលទន្ទឹងរង់ចាំព្យាការីម្នាក់ ដូច្នេះជនជាតិយូដាមួយចំនួន បានទទួលស្គាល់ថាព្រះយេស៊ូជាព្យាការីនោះ ព្រះយេស៊ូជាព្រះបុត្រាដែលយាងមកដើម្បីសង្គ្រោះគេ ដូច្នេះគេដើរតាមព្រះយេស៊ូ។ តែពេលចាប់ផ្តើមចេញពីវប្បធម៌ អរិយធម៌សាសនាយូដា ចេញពីប្រជាជនដែលកាន់សាសនាយូដាដែលជឿលើព្រះជាម្ចាស់តែមួយអង្គគត់ ដែលជាព្រះជាម្ចាស់របស់លោកអប្រាហាំ លោកអ៊ីសាក លោកយ៉ាកុប គេទៅដល់ទីក្រុងជុំវិញសមុទ្រមេឌីទែរ៉ាណេ ទៅដល់ទីក្រុងរ៉ូម ជួបជាមួយមនុស្សដែលមានសាសនាដូចគ្នា ដែលគ្មានសាសនាយូដាទេ តែមនុស្សមួយចំនួនគេមិនចង់ស្តាប់ទេ។ ពេលលោកប៉ូល ចាប់ផ្តើមនិយាយនៅទីក្រុងអាថែន អំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ គេលែងស្តាប់អស់ហើយ។ ពេលទៅដល់ទីក្រុងរ៉ូមក៏ពិបាកដែរ មានគេសង្ស័យច្រើនថាយេស៊ូជានរណា? នៅទីក្រុងរ៉ូម គេគោរពអាទិទេពនានា ដូចជាព្រះអាទិត្យ ព្រះចន្ទ និងព្រះផ្សេងៗ នៅឆ្ងាយពីវប្បធម៌ អរិយធម៌សាសនាយូដា ដែលជាសាសនាកំណើតរបស់ព្រះយេស៊ូដែរ គេទទួលការបៀតបៀនច្រើនទៅៗ។

នៅឆ្នាំ៥២ ក្រុមគ្រីស្តទូតប្រជុំក្នុងទីក្រុងយេរ៉ូសាឡឹម និងគិត **តើសាសន៍ដទៃដែលមិនមែនកាន់សាសនាយូដា អាចចូលនៅក្នុងសាសនារបស់ព្រះយេស៊ូ ទៅជាសាវ័ករបស់ព្រះយេស៊ូតែម្តងបានឬទេ?** គេសម្រេចចិត្តថាបាន ដោយមិនចាំបាច់ឆ្លងកាត់ប្រពៃណីសាសនាយូដាទាំងអស់។ យើងជាជនជាតិអ្វីក៏ដោយ យើងកាន់សាសនាណាក៏ដោយ យើងអាចទៅជាសាវ័ករបស់ព្រះគ្រីស្ត។ ឆ្នាំ៦៤ នៅទីក្រុងរ៉ូមមាន បញ្ហាមួយយ៉ាងធំគឺឆេះទីក្រុងរ៉ូម ផ្ទះជាច្រើនឆេះអស់ ប្រជាជនស្លាប់ច្រើន។ ព្រះចៅអធិរាជ ដែលមានចិត្តស្អប់គ្រីស្តបរិស័ទបានចោទប្រកាន់ថា ទីក្រុងរ៉ូមឆេះដោយសារគ្រីស្តបរិស័ទ។ ដូច្នេះ គេចាប់ផ្តើមចាប់គ្រីស្តបរិស័ទយកទៅឲ្យសត្វស៊ីធ្វើជាល្បែងកំសាន្ត គេចាប់លោកប៉ូលកាត់ក គេចាប់លោកសិលាឆ្កាងបញ្ច្រាស់ក្បាលចុះក្រោម គេបៀតបៀនគ្រីស្តបរិស័ទយ៉ាងខ្លាំងមែនទែន។ ក៏ប៉ុន្តែ គ្រីស្តបរិស័ទមិនអស់សង្ឃឹមទេ គ្រីស្តបរិស័ទចាប់ផ្តើមមាននៅទីក្រុងរ៉ូម ទោះបីគេដឹងថាមានការបៀតបៀនរហូតដល់សម្លាប់ ចាប់យកទៅឲ្យសត្វស៊ី ឬកាត់ក ឬឆ្កាង យ៉ាងសាហាវបំផុត។ គ្រីស្តបរិស័ទបន្តរៀបចំ អ្វីដែលគេអាចធ្វើបាន គេរៀបចំការអធិដ្ឋានរបស់គេ សម័យនោះគ្មានវិហារទេគេគ្មានសិទ្ធិកសាងព្រះវិហារ ដូច្នេះ គេជួបជុំគ្នាតាម

ផ្ទះ។ ផ្ទះនេះទៅជាកូនវិហារមួយ ដែលគេហៅជាភាសាឡាតាំង «Domus Ecclesia» មានន័យថា ផ្ទះមួយជាព្រះវិហារមួយ (ព្រះសហគមន៍មួយ) ដែលគេជួបជុំគ្នាដើម្បីអធិដ្ឋាន គ្រីស្តបរិស័ទគ្មានសេរីភាព កាន់សាសនាផ្លូវការ ប៉ុន្តែគេចាប់ផ្តើម។ នៅពេលគេធ្វើបុណ្យសព ក្នុងទីក្រុងរ៉ូមគ្មានសិទ្ធិកប់សព ដូច្នេះគេធ្វើក្រៅទីក្រុងនៅក្រោមដី ដូច្នេះក្រោមទីក្រុងរ៉ូមដូចជាមានទីក្រុងមួយទៀតមានសុទ្ធតែផ្នូរ ដែលគេកាយនៅក្រោមដី គេដាក់សពរបស់គ្រីស្តបរិស័ទពីដើម ក៏ដូចជាសពរបស់ជនជាតិរ៉ូម៉ាំងដែរ។ គ្រីស្តបរិស័ទមានទម្លាប់ ជួបជុំគ្នានៅកន្លែងហ្នឹង ដើម្បីអធិដ្ឋាន ដើម្បីបរិភោគអាហារ នៅក្នុងធម៌មេត្តាករុណា ដែលគេហៅអាហ្គាប៉េ «AGAPE» គេអធិដ្ឋាននៅក្នុងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ គេអធិដ្ឋាននៅក្នុងធម៌មេត្តាករុណា ជួបជុំគ្នាផង ញ៉ាំអាហារផង ធ្វើអគ្គសញ្ញាព្រះកាយព្រះគ្រីស្តផង រួមជាមួយអ្នកដែលស្លាប់ហើយ នៅកន្លែងមួយដែលមិនអាចចាប់គេបាន ដោយសារគេនៅក្រោមដី ប៉ុន្តែគេនៅបន្តអធិដ្ឋាន។ នៅក្នុងកន្លែងហ្នឹងយើងរកឃើញ រូបកូនវិហារតូចលើជញ្ជាំង ជាកន្លែងដែលយើងរកឃើញរូបព្រះនាងម៉ារីចាស់ជាងគេនៅក្នុងពិភពលោកដែលនៅមានរហូតដល់សព្វថ្ងៃ។ ជាកន្លែងដែលយើងរកឃើញរបៀបដែលគ្រីស្តបរិស័ទអធិដ្ឋានពីដើម ដែលឃើញមានរូបនៅលើជញ្ជាំងនោះអាយុជាង២០០០ឆ្នាំ។ ជាកន្លែងដែលគេគូររូប ជាពិសេសអំពីសម្តន្ធមេត្រីចាស់ ជារបៀបដែលគេអប់រំអ្នកថ្មីៗ ព្រោះគេអត់ចេះអានទេ អត់មានសៀវភៅ អត់មានរោងបោះពុម្ព ដូច្នេះគេមើលតាមជញ្ជាំងដែលគេគូសរូប ដើម្បីអប់រំជំនឿ ឲ្យគេយល់កាយវិការ យល់អំពីព្រះនាងម៉ារីដែលមានកូនគឺព្រះយេស៊ូនៅក្នុងដៃគាត់ ឲ្យគេយល់អំពីសម្ពន្ធចាស់។ នេះជារបៀបដែលគេធ្វើពីដើម គេអត់ដែលលះបង់ចោល គេខិតខំរកមធ្យោបាយ។

នៅឆ្នាំ៣១៣ មានចៅអធិរាជរ៉ូម៉ាំងឈ្មោះកុងស្តង់តាំង បានកែប្រែចិត្តគំនិតទៅជាគ្រីស្តបរិស័ទ នាំឲ្យគ្រីស្តបរិស័ទអាចជួបជុំគ្នាជាផ្លូវការ និងមានសិទ្ធិសាងសង់វិហារ។ ជាចៅអធិរាជដែលជួយជំរុញឲ្យព្រះសហគមន៍មានកម្លាំង។ ឆ្នាំ៣២៥ លោកអភិបាលប៉ុន្មានអង្គដែលមាននៅក្នុងពិភពលោក (ក្រុងរ៉ូមនិងប្រទេសក្រិច) ជួបជុំគ្នា ហើយគេបានបង្កើតធម៌ប្រកាសជំនឿនៅនីសេ មាន២០មាត្រានៃច្បាប់ព្រះសហគមន៍។ យើងឃើញនៅក្នុងកាលៈទេសៈពិបាក ការបៀតបៀន គេជួបជុំគ្នា អធិដ្ឋាន អប់រំជំនឿ យកផ្ទះដើម្បីជាកន្លែងថ្វាយអភិបូជា ដើម្បីជួបគ្នាជាគ្រីស្តបរិស័ទ ដើម្បីថែរក្សាជំនឿដែលគេបានទទួលពីគ្រីស្តទូតផ្ទាល់។

នៅប្រទេសជប៉ុន សន្តហ្វ្រង់ស្វ័រសាវីយេ៉បានទៅប្រកាសដំណឹងល្អ នៅឆ្នាំ១៥៨៧ព្រះចៅអធិរាជនៅជប៉ុនចាប់ផ្តើមអន់ចិត្តជាមួយសាសនទូតបរទេស ដូច្នេះគាត់ប្រកាសឲ្យបណ្តេញសាសនទូតចេញ តែពេលនោះគេមិនសូវអនុវត្តតាម ហេតុនេះហើយសាសនទូតអាចបន្តនៅ

ខ្លះៗបាន។ ប៉ុន្តែ ឆ្នាំ១៥៩៧ គេចាប់គ្រីស្តបរិស័ទជនជាតិជប៉ុនមួយចំនួន ហើយឲ្យគេធ្វើដំណើរ នៅក្នុងរដូវរងាពីទីក្រុងក្យូតូ ទៅទីក្រុងណាហ្គាសាគីដែលមានចំងាយ១០០០គីឡូម៉ែត្រ ហើយ បានឆ្កាងពួកគេ ចំនួន២៧នាក់ ដែលជាមរណសាក្សីនៅណាកាសាគីសព្វថ្ងៃ។ នៅឆ្នាំ១៦១២ រដ្ឋ អំណាចជប៉ុនបានសម្លាប់គ្រីស្តបរិស័ទ៥ម៉ឺននាក់ គ្រីស្តបរិស័ទមុនគេសម្លាប់គេបានដាក់រូបព្រះ នាងម៉ារី រូបព្រះយេស៊ូនៅលើដីបើអ្នកណាព្រមជាន់គេនឹងរួចជីវិត តែបើមិនព្រមជាន់គេនឹងសម្លា ប់។ មានខ្លះគេរត់គេចខ្លួនទៅកាន់កោះតូចៗ ឬនៅក្នុងព្រៃ រយៈពេល២៥០ឆ្នាំគេអត់មានបូជាចា រ្យ អត់មានគ្រូអប់រំជំនឿ អត់មានបងស្រី អត់មានអ្វីសោះ មានតែជំនឿដែលគេបានទទួលពីប្រាំង ស្វ័រសាវីយេ និងសាសនទូតពីដើម គេចាំតែធម៌ឱព្រះបិតា បពិត្រព្រះនាងម៉ារី ធម៌ជឿ និងគេចាំ ពាក្យដើម្បីធ្វើពិធីជ្រមុជទឹកជាភាសាឡាតាំង។ នៅក្នុងព្រៃគេបានយកអសនៈសាសនាធម្មជាតិ ដែលគេហៅសាសនាឈីនតូ កែច្នៃជាឈើឆ្កាងជាអសនៈរបស់គេ។ ពុទ្ធសាសនានៅប្រទេស ជប៉ុន គេគោរពព្រះពុទ្ធស្រី គេហៅកាណុន គេបានកែរូបហ្នឹងជាព្រះនាងម៉ារី។ ២៥០ឆ្នាំអត់មាន បូជាចារ្យ អត់បងស្រី គ្មានសិទ្ធិជួបជុំគ្នាជាផ្លូវការ ប៉ុន្តែគេបានថែរក្សាជំនឿរបស់គេអស់៧ជំនាន់។ នៅឆ្នាំ១៨៦១ សាសនាទូតបានរកឃើញគ្រីស្តបរិស័ទមួយម៉ឺននាក់នៅក្នុងព្រៃ ដែលបានបន្ត ជំនឿឲ្យគ្នាដោយចាំថាបុណ្យណូអែលនៅថ្ងៃណា បុណ្យចម្លងនៅថ្ងៃណារាល់ឆ្នាំ។

ព្រះសហគមន៍កម្ពុជាយើងនៅឆ្នាំ១៩៧០ នៅពេលមានយប់មួយគេហៅយប់កាប់យួន មានប៉ុន្មានពាន់នាក់ត្រូវរត់ទៅប្រទេសវៀតណាម នៅក្បែរវិហារយើងមានរាប់ម៉ឺននាក់ដែលគេ សម្លាប់ ទន្លេមេគង្គឡើងពណ៌ក្រហមដោយសារឈាមរបស់គ្រីស្តបរិស័ទយើង។ នៅពេលនោះ យើងចូលនៅក្នុងសម័យ លន់នល់ សង្គ្រាមស៊ីវិល នៅសល់គ្រីស្តបរិស័ទខ្មែរយើងប៉ុន្មាននាក់ ដែលអធិដ្ឋានតាមដែលអាចធ្វើបាន។ ស្ពានជ្រោយចង្វារត្រូវគេបាញ់(កំទេច) ឆ្លងលែងបាន ប៉ុន្តែ លោកសាឡាស់ លោកសាឡឹម និងលោកសម្រេន បន្តថ្វាយអភិបូជាអស់ពីសមត្ថភាព។ រហូត ដល់បុណ្យចម្លងចុងក្រោយឆ្នាំ១៩៧៥ ថ្ងៃទី៣០ ខែមីនា លោកសាឡឹម ជិះកាណូតដើម្បីទៅមាត់ ក្រសាស់ និងពោធិ៍ធំ ប្រាប់គ្រីស្តបរិស័ទថាថ្ងៃនេះបុណ្យចម្លង ឲ្យយើងថ្វាយអភិបូជានៅក្នុង អំណរសប្បាយ។ យាយៗថាអត់បានទេលោកឪពុកសង្គ្រាមអស់ហើយ ប៉ុន្តែគេបានធ្វើដោយ បង្ហាញសេចក្តីសង្ឃឹមដែលគេមាន។ លោករ៉ាមូស ចាប់លោកឆ្មារសាឡាស់ធ្វើជាអភិបាល ពេល ធ្វើជាអភិបាលជាផ្លូវការ យើងត្រូវមានលោកអភិបាលបីអង្គ ដើម្បីតែងតាំង។ ថ្ងៃហ្នឹងមានតែ លោករ៉ាមូសម្នាក់ឯង ព្រលានយន្តហោះបិទទ្វារអស់ហើយ ព្រំដែនបិទទ្វារអស់ហើយ វិសាល វិហាររបស់យើងដែលនៅជាប់សាលាក្រុងភ្នំពេញមិនអាចចូលបានទេ។ ដូច្នេះ សល់វិហារតែមួយ គឺវិហារព្រះមាតា (មណ្ឌលសុខភាពសព្វថ្ងៃ) ជាមួយគ្រីស្តបរិស័ទ៤-៥នាក់ នៅពេលថ្វាយអភិ

បូជាមានគ្រាប់ផ្លោងបីដងនៅក្នុងវិហារ គ្រីស្តបរិស័ទលាក់ខ្លួនក្រោមកៅអី។ គេបណ្តេញសាសនទូតទាំងអស់ បងស្រីមួយចំនួនធំទៅបារាំង ទៅវៀតណាម... គ្រីស្តបរិស័ទលែងធ្វើអ្វីបានទាំងអស់ គេទៅតាមផ្លូវនៅគ្រប់ទីកន្លែង លោកឆ្មារ សាឡាស់ សាឡឹម សម្រើន ទៅដល់តាំងគោក នៅពេលនោះគេអត់មានសិទ្ធិធ្វើអ្វីសោះ ប្រសិនបើយើងអភិបូជាគេចាប់ភ្លាមយកទៅអប់រំ។ ដូច្នេះ លោក ឆ្មារ សាឡាស់ បានចុះឈ្មោះនៅក្នុងក្រុមកងចល័ត ដើម្បីធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ដើម្បីមានឱកាសជួបគ្រីស្តបរិស័ទ។ យូរៗម្តងគាត់ឃើញគ្រីស្តបរិស័ទម្នាក់ ធ្វើព្រះពរតូចមួយ ញញឹមមួយ ដោយស្ងាត់ៗកុំឲ្យធ្វើខុស។ ពេលខ្លះសាឡឹម និងសាឡាស់ ជាមួយសម្រើន នៅតាំងគោកគេអង្គុយលើគ្រែធ្វើដូចហូបបាយ តាមពិតគេថ្វាយអភិបូជាស្ងាត់ៗ ដោយមានបងប្រាកដនៅខាងមុខដើម្បីពិនិត្យមើលយាមផ្លូវ។ ពេលលោកសាឡាស់ ស្លាប់ នៅក្នុងខោរបស់គាត់គេរកឃើញសៀវភៅគម្ពីរជាភាសាបារាំងដ៏តូចមួយដែលគាត់បានថែរក្សា។ នៅសម័យប៉ុលពត អ្នកដែលចេះអានគេយកទៅអប់រំភ្លាម ជាពិសេសបើអានសៀវភៅដែលមកពីបរទេស មកពីសត្រូវអាមេរិក ឬបារាំង គេនឹងបាញ់ចោលភ្លាម ប៉ុន្តែគាត់បានថែរក្សាព្រះបន្ទូលព្រះជាម្ចាស់អស់ពីដួងចិត្ត។ ដូច្នេះ នេះហើយគ្រីស្តបរិស័ទរបស់យើងគ្មានអភិបូជាក្នុងប្រទេសកម្ពុជា ពេលផុតសម័យខ្មែរក្រហមហើយ ប៉ុន្តែនៅជំរុំមានបូជាចារ្យមួយចំនួនដូចជាលោកតាប៉ុងសូរង់ លោកតាវីណោជាដើម។ គ្រីស្តបរិស័ទធ្វើដំណើរដល់ព្រំដែនខ្មែរ-ថៃ ជួបជាមួយលោកតាវីណោផ្ញើព្រះកាយដែលគាត់បានរៀបចំដាក់ក្នុងកំប៉ុង ហ្វីលរូបថត ផ្ញើទៅគេដើម្បីឲ្យគេជួបជុំគ្នាអធិដ្ឋាន ទទួលព្រះកាយ ក្នុងពេលវេលាដែលអត់មានបូជាចារ្យក្នុងប្រទេសកម្ពុជានាពេលនោះ។

បងប្អូនជាទីស្រឡាញ់!

យើងឃើញព្រះសហគមន៍ អត់ដែលលះបង់ចោលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត អត់ដែលលះបង់ចោលអគ្គសញ្ញាជ្រមុជទឹក ព្រះសហគមន៍អត់ដែលលះបង់ចោលការអធិដ្ឋាន ព្រះសហគមន៍អត់ដែលលះបង់ចោលការបន្តជំនឿ ក្នុងកាលៈទេសៈណាក៏ដោយ ការបៀតបៀនបែបណាក៏ដោយ បញ្ហាណាក៏ដោយ។ ដូច្នេះ យើងរស់នៅក្នុងសម័យកូវីដ១៩ យើងអត់មានសិទ្ធិជួបជុំគ្នាបែបសាសនា យើងអត់មានសិទ្ធិជួបជុំក្រុមធំ ក៏ប៉ុន្តែយើងត្រូវការគិតពិចារណាដែរ។ សប្តាហ៍នេះខ្ញុំបានហៅមេក្រុមកាយឫទ្ធិ ក្រុមយុវជននៅក្នុងភូមិភាគភ្នំពេញទាំងអស់ ពីម្សិលមិញនិងថ្ងៃនេះឲ្យមានឱកាសជួបជុំគ្នា៥នាក់ ១០នាក់ ប្រមូលលុយខ្លះគិតគូរ **តើខ្ញុំជាយុវជនកាតូលិកម្នាក់នៅក្នុងភូមិភាគភ្នំពេញ ខ្ញុំអាចធ្វើអ្វីខ្លះដើម្បីលើកទឹកចិត្តបងប្អូនដែលកំពុងពិបាក?** ដូចក្រុមឧបដ្ឋាកពីដើមដែលគ្រីស្តទូតបានជ្រើសរើសដើម្បីបម្រើគុ។ កុំភ្លេចសាលារៀនបិទទ្វារ កូនតូចៗរៀនថ្នាក់ទី១ ទី២ ទី៣ ប្រហែលអត់មានឱកាសដើម្បីរៀនពីចម្ងាយ (E-Leaning) បងៗដែលជាយុវជនយុវនារី

យកមួយថ្ងៃមួយម៉ោងដើម្បីអង្គុយជាមួយប្អូនៗ ក្មួយៗដោយអានមេរៀនរំលឹកកុំឲ្យគាត់ស្ពឹក។ ប្រមូលលុយតិចតួចដើម្បីជួយអ្នកក្រីក្រម្នាក់ ដើម្បីជួយអ្នកជំងឺម្នាក់ យុវជនយុវនារីនិងមេក្រុមកាយប្ញទ្ធិត្រូវតែធ្វើគំរូ ប៉ុន្តែបម្រើតុមិនទាន់ល្មមទេ។ គ្រីស្តបរិស័ទមិនអាចបាត់បង់អគ្គសញ្ញាព្រះកាយព្រះគ្រីស្ត មិនត្រឹមតែមើលអភិបូជាអនឡាញតែប៉ុណ្ណឹង នេះមិនមែនជារបៀបរបស់ព្រះសហគមន៍ទេ។ ដូច្នេះ ខ្ញុំអញ្ជើញទាំងគ្រីស្តបរិស័ទ ទាំងបូជាចារ្យ ទាំងបងស្រី បព្វជិតបព្វជីតានៅក្នុងភូមិភាគភ្នំពេញទាំងមូល ដោយទទួលពន្លឺពីព្រះវិញ្ញាណដ៏វិសុទ្ធ ដោយអធិដ្ឋាន រកឃើញនៅតាមកន្លែងដែលយើងនៅ នៅទីក្រុងក្តី នៅជនបទក្តី **តើយើងអាចធ្វើដូចម្តេច ដើម្បីឲ្យយើងបង្កើតដូមូសអ៊ីក្លេសេតូចៗ ផ្ទះដែលជាព្រះវិហារតូចៗ?** យកចិត្តទុកដាក់ទៅតាមផ្ទះគ្រីស្តបរិស័ទមួយចំនួនដើម្បីអភិបូជា ព្រោះយើងមិនអាចហៅគ្រីស្តបរិស័ទមកព្រះវិហារបាន។ គ្រីស្តបរិស័ទត្រូវតែទទួលខុសត្រូវដែរ គឺត្រូវអញ្ជើញលោកឪពុកទៅ ដោយមិនចាំឲ្យតែលោកឪពុកទៅឡើយ យើងអញ្ជើញបាន យើងមានលោកឪពុកជាង៤០នាក់នៅក្នុងភូមិភាគភ្នំពេញ យើងមាន២០នាក់នៅរាជធានីភ្នំពេញ។ អត់មានលោកអភិបាលណាម្នាក់ ដែលហាមឃាត់មិនឲ្យថ្វាយអភិបូជា អត់មានរដ្ឋអំណាចណាមួយនៅក្នុងពិភពលោកដែលហាមឃាត់មិនឲ្យថ្វាយអភិបូជាបានទេ។ ដូច្នេះ យើងត្រូវតែគិត ព្រះយេស៊ូជាផ្លូវ ព្រះយេស៊ូជាជីវិត ព្រះយេស៊ូជាសេចក្តីពិត នៅក្នុងពេលវេលាហ្នឹងដែលប្រហែលអាចនៅយូរទៀត ១ខែ ២ខែ ៣ខែ។ យើងមិនអាចណែនាំឲ្យគ្រីស្តបរិស័ទយើង បាត់បង់អគ្គសញ្ញាព្រះកាយព្រះគ្រីស្តដែលជាជីវិតមកពីព្រះយេស៊ូផ្ទាល់។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទកាតូលិក យើងមិនទំនាក់ទំនងរវាងយើងនិងព្រះជាម្ចាស់តែប៉ុណ្ណឹង យើងមានព្រះសហគមន៍ដែលជាអគ្គសញ្ញារបស់ព្រះគ្រីស្ត និងមានអគ្គសញ្ញានានាជាពិសេសអគ្គសញ្ញាព្រះកាយព្រះគ្រីស្តដែលចិញ្ចឹមយើង ដែលជាប្រភពនៃជីវិត ដែលជាកម្លាំងនៃជីវិតរបស់យើងទៀត។ ដូច្នេះ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធយើងអាចរកមធ្យោបាយច្រើន ថ្ងៃនេះខ្ញុំទេសនាយូរអំពីប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍និងគ្រីស្តបរិស័ទពីដើម ទាំងនៅប្រទេសជប៉ុន និងប្រទេសកម្ពុជាយើង ដើម្បីយល់ថានៅក្នុងកាលៈទេសៈណាក៏ដោយ នៅគ្រាពិបាកណាក៏ដោយ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធយើងមានសមត្ថភាពប្រកាសជំនឿ ដើម្បីបន្តទទួលព្រះកាយព្រះគ្រីស្ត ដើម្បីបន្តរស់នៅជាគ្រីស្តបរិស័ទប្រចាំថ្ងៃនៅក្នុងសង្គម។

ព្រះសហគមន៍របស់យើង មិនមែននៅជាប់ក្នុងបន្ទប់ដូចមុនពេលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកទេ គ្រីស្តបរិស័ទយើងជាប្រជារាស្ត្រនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមក២០០០ឆ្នាំមុន ហើយបានជំរុញឲ្យគេចេញដើម្បីប្រកាសដំណឹងល្អ។ ថ្ងៃនេះ យើងនៅបានដោយសារព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមក ប្រសិនបើក្រុមគ្រីស្តទូតបិទទ្វារចាក់សោររហូត ថ្ងៃ

នេះយើងមិននៅទីនេះទេ សាសនាយេស៊ូដាច់ខ្យល់ពីយូរហើយ ដំណាលនឹងគ្រីស្តទូតស្លាប់។ ប៉ុន្តែដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ យើងនៅទីនេះថ្ងៃនេះពីព្រោះគ្រីស្តទូតបានទៅ ដោយឆ្លងកាត់ការបៀតបៀន តស៊ូដើម្បីណែនាំឲ្យព្រះសហគមន៍របស់យើងមានជីវិត។ ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ដែលគង់នៅជាមួយយើង យើងស្តាប់ហើយស្តាប់ទៀត ខ្ញុំជាផ្លូវ ខ្ញុំជាសេចក្តីពិត និងខ្ញុំជាជីវិត។ អាម៉ែន៕